# ការសម្ភាសន៍របស់ អ៊ុំ គាត ហ៊ុន

**ក៖ អ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណារិទ្ធ    ខ៖ អ្នកត្រូវគេសម្ភាសន៍ឈ្មោះគាត ហ៊ុន**

## ពត៌មានសង្ខេបរបស់ អ៊ុំស្រី គាត ហ៊ុន

សព្វថ្ងៃនេះអ៊ុំស្រីគាត ហ៊ុនមានអាយុ៦០ឆ្នាំហើយ គាត់មានកើតនៅឆ្នាំឆ្លូវ ខែបុស្រ ថ្ងៃព្រហស្បត៍។ គាត់មានស្រុកកំណើតនៅភ្នំក្រោម ខេត្តសៀមរាប គាត់មានបងប្អូន៥នាក់ហើយគាត់ជាកូនទី២ក្នុងគ្រួសារ។ កាលពីសម័យប៉ុល ពតគាត់ត្រូវបានជម្លៀសទៅខាងខេត្តបាត់ដំបងជាមួយម្ដាយនិងប្អូនស្រី៧របស់គាត់។

ក៖ បាទជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ុំដែលបានឲ្យខ្ញុំសម្ភាសន៍ពីប្រវត្តិរបស់ អ៊ុំ ហើយការសម្ភាសន៍ណឹងត្រូវបានរៀបចំដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថាព្រីហាំយ៉ង់ដែលនៅឯសហរដ្ឋអាមេរិក។ បាទ គោលបំណងរបស់សាកលវិទ្យាល័យគឺចង់សម្ភាសន៍ប្រវិត្តប្រជាជនខ្មែរ ដើម្បីរក្សារទុកប្រវិត្តប្រជាជនខ្មែរដើម្បីឲ្យ កូនចៅជំនាន់ក្រោយរបស់អ៊ុំអាចស្គាល់ពីប្រវិត្តរបស់ជីដូនជីតាហើយរៀនអំពីប្រវិត្តរបស់ពួកគាត់ណាអ៊ុំ បាទហើយចឹងនៅពេលដែលខ្ញុំសម្ភាសន៍អ៊ុំចប់ ខ្ញុំនឹងដាក់ការសម្ភាសន៍របស់អ៊ុំណឹងនៅក្នុងវេបសាយរបស់សាលាដែលមានឈ្មោះថា www.cambodianoralhistory.byu.edu ណាអ៊ុំ ចឹងតើអ៊ុំយល់ព្រមឲ្យខ្ញុំដាក់សម្ភាសន៍របស់អ៊ុំចូលទៅក្នុងវេបសាយរបស់សាលាទេអ៊ុំ?

ខ៖ ចាស យល់ព្រមអ្នកគ្រូ។

ក៖ បាទសម្រាប់ថ្ងៃខែដែលខ្ញុំសម្ភាសន៍អ៊ុំនេះគឺ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ ហើយការសម្ភាសន៍នេះត្រូវបានធ្វើឡើងនៅភូមិចុងឃ្មៀស ឃុំចុងឃ្មៀស ក្រុងសៀមរាប ខេត្តសៀមរាប

ណាអ៊ុំណា ហើយខ្ញុំជាអ្នកសម្ភាសន៍ឈ្មោះ ហេង សុវណ្ណនរិទ្ធ អញ្ចឹងខ្ញុំចង់សួរថាតើអ៊ុំមានឈ្មោះពេញឈ្មោះអ្វីដែរអ៊ុំ?

ខ៖ ឈ្មោះគាត ហ៊ុន។

ក៖ គាត ហ៊ុន?

ខ៖ ចាស គាត ហ៊ុន។

ក៖ បាទ ចុះអ៊ុំមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖ អត់ទេអ្នកគ្រូ។

ក៖ ចុះអ៊ុំមានអាយុប៉ុន្មានហើយឆ្នាំនេះ?

ខ៖ ខ្ញុំ៦០ឆ្នាំ។

ក៖ ចុះអ៊ុំចាំថ្ងៃខែឆ្នាំកំណើតអ៊ុំបានទេអ៊ុំ?

ខ៖ ខ្ញុំចាំតែខែខ្មែរអ្នកគ្រូ ខ្ញុំឆ្នាំឆ្លូវ ខែបុស្រ ថ្ងៃព្រហស្បត៏។

ក៖ ឆ្នាំបារាំងអត់ចាំទេ?

ខ៖ អត់។

ក៖ បាទ ចុះអ៊ុំមានស្រុកកំណើតនៅឯណាដែរអ៊ុំ?

ខ៖ ចាស ស្រុកកំណើតកើតជាខ្ញុំនៅភ្នំក្រោមនេះឯងអ្នកគ្រូ។

ក៖ អត់ដែលផ្លាស់ប្តូរទីលំនៅទៅណាទេ?

ខ៖ ផ្លាសតែពីកាលជំនាន់អាពតដែលវាបញ្ជូនយើងទៅណឹងឯង ចាសដល់យើងវៀតណាម វាយដាច់មកចូលមកនៅស្រុកវិញណឹងឯង។

ក៖ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ បងប្អូន៥នាក់អ្នកគ្រូ។

ក៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មានដែរអ៊ុំ?

ខ៖ ស្រី៤ ប្រុស១ ។

ក៖ ហើយអ៊ុំជាកូនទីប៉ុន្មានដែរចឹង?

ខ៖ ខ្ញុំទី២។

ក៖ ចុះអ៊ុំអាចរៀបរាប់ឈ្មោះបងប្អូនទាំងអស់របស់អ៊ុំបានទេពីបងគេរហូតដល់ពៅគេណាអ៊ុំ?

ខ៖ ចាស បងស្រី១ឈ្មោះគាតយ៉ាន ចាសទី២មកខ្ញុំគាត ហ៊ុន ទី៣មកគាតហួរដើរមិញ ទី៤មកគាតកាងប្រុស ទី៥មកគាតពៅស្រីផ្ទះខ្ញុំអង្គុយមិញណា ពៅគេ៥នាក់។

ក៖ ចុះអ៊ុំមានចងចាំប្រវិត្តអ្វីខ្លះឬក៏សាច់រឿងអ្វីខ្លះដែរធ្លាប់ធ្វើជាមួយបងប្អូនណា?

ខ៖ បងប្អូន?

ក៖ បាទ ធ្វើអ្វីខ្លះដែរជាមួយបងប្អូនកាលពីក្មេងៗ?

ខ៖ ពីក្មេងៗដែលខ្ញុំនៅក្មេងដែលខ្ញុំនៅក្មេងអ្នកគ្រូដែលនៅតូចៗពីមុនជំនាន់ប៉ុល ពត មក នៅក្នុងសង្គមម៉ែប៉ា ចាសដល់មកយើងឆ្នាំ៧៤ ៧៥នេះវាជំនាន់ប៉ុល ពតហើយចាសបើចឹងហើយគេដូចថាគេឧបមាថាគេបំបែកបងប្អូនយើងគេអត់ឲ្យនៅជុំគ្នាទេ តែចាប់ផ្ដើមពីអាយុ១០ឆ្នាំឡើងលើគេបំបែកយើងអ្នកគ្រូគេអត់ឲ្យជុំជាមួយឪពុកម្ដាយទេគេដកយើងទៅដាក់តាមកុមារមន្ទីរទៅ ចូលចល័តទៅអ្នកណាអាយុច្រើនតិចអីចឹងណាចាសគេយកទៅចូលចល័តទៅបើចឹងហើយយើងអត់បានថែរក្សាបងប្អូនទេ ចាសដល់សរុបរួមមកដល់មកវៀតណាមវាយដាច់យើងនេះ បងប្អូនយើងធំៗអស់ហើយបានជួបជុំម៉ែឪយើងវិញ ចាសដល់ចឹងហើយខ្លះគេបានប្ដីទៅខ្លះគេបានប្រពន្ធទៅ អញ្ចឹងណា ចាសនៅដោយឡែកៗពីគ្នា។

ក៖ ចុះកាលពីសម័យប៉ុល ពតណឹងអ៊ុំមានអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំជំនាន់ប៉ុល ពតអាយុ១៨ឆ្នាំអ្នកគ្រូ។

ក៖ ចឹងមានន័យថាចូលកងនារី?

ខ៖ ចាសចូលកងនារីអី គេដាក់ចូលទៅកងចល័តតែម្ដង ចល័តនោះវេទនាណាស់លោកគ្រូបើនិយាយពីរឿងអាពតវិញ២យប់ ២ថ្ងៃនិយាយមិនអស់ទេខ្ញុំ។

ក៖ បាទសុំនិយាយឲ្យខ្ញុំ២ម៉ោងមកចឹង។

ខ៖ វាវេទនាយ៉ាងម៉េចអ្នកគ្រូ ម៉ែប៉ាខ្ញុំ ប៉ាខ្ញុំគេយកមកនៅថាគេហៅថាភូមិភាគនៅឯព្រៃកទាល់ឯណោះ ចាសខ្ញុំជាមួយម្ដាយ ជាមួយប្អូនពៅមួយនោះ គេទុកខ្ញុំនៅឯអូរតាគីយើងឯ?

ក៖ បាត់ដំបង?

ខ៖ ចាស បាត់ដំបង ហួសបាត់ដំបងទៀតអ្នកគ្រូ ដល់ពេលណឹងអ្នកគ្រូអើយបបរព្រលិត ខ្ញុំហើមខ្លួនប៉ុណ្ណេះ ហើយមីប្អូនពៅគេនេះនៅតូចនេះ វានៅដូចថាអាយុ៦ ៧ឆ្នាំ ប៉ុនជំនាន់ណឹងអត់បាយនោះ ទៅក៏វាស្គមនៅតែស្បែកដណ្តប់ឆ្អឹងចឹងទៅពរប្អូនមួយចំហៀងដៃមួយចំហៀងយួរបបរ អ្នកគ្រូអើយដួលបាក់ចង្កេះសព្វថ្ងៃឡើងដំណើរដូចចិនហើយសព្វថ្ងៃ ចាសវាដួលអុកមួយចំហរចឹងទៅប្អូនផងបបរផងទៅសន្លប់ប្រហែល២ម៉ោង ទម្រាំបានដឹងខ្លួនព្រោះខ្លួនហើមប្រះចេញទឹក វេទនាណាស់អ្នកគ្រូ ហើយបងប្អូនបងស្រីមួយនោះ បងស្រីនោះ គេបញ្ជូនទៅនៅស្អីឯណាទេគេហៅទូលចារអីឯណានោះ ជាមួយប្អូនអាប្រុសមួយ។ ចាសដាច់ៗដោយឡែកពីគ្នាខ្ញុំនេះម្តាយចាស់ផង ប្អូនតូចទៀត ក្រញៀកប្អូនហើយទីងណាត់ទីងណែង អត់បាយផងថ្ងៃឡើងចឹងគេឲ្យយើងទៅ រើសករស្រូវចឹងទៅ ទៅកាប់អាត្រផាងខែត្រម៉េចទេគេឲ្យមកធ្វើអាដែងនេះ ទៅៗគេឲ្យខ្ញុំបារបង្គន់អាចម៍ថាអូយវេទនាណាស់ជំនាន់អាពត ចាសថ្ងៃឡើងចេះផុតពីការងារចេះ ត្រកួនដុះវិញៗតាមមាត់ប្រឡាយណា បេះបុិចៗបានតែស្លឹកបានតែត្រួយតិចៗណឹង មក យកមកនៅត្នែកសរត្នែកខ្មៅចឹងអ្នកគ្រូ មើលតែរាងស្វាត់គេចឹងជីកដីទ្រជ្រៅចឹងទៅ ដាក់អាកូនឆ្នាំងយើងតូចចឹងទៅជីកដីចន្លុះឆ្នាំងចឹងទៅអ្នកគ្រូខ្ញុំឆ្លាតណាស់និយាយទៅថាដូចអួតខ្លួនឯងម៉ង ហើយចេះពុះឆ្អិនដែរតើ ចាសជីកដីទៅចន្លុះក្នុងឆ្នាំងណឹងទៅក្នុងដីណឹងទៅ ទៅយើងលប់ដីបិទគំរប់ឲ្យជិតទៅយើងបិទគម្រប់ពីលើ ចាសយើងលុបដីពីលើណឹងទៅយើងដុតធ្វើដូចជាយើង ដូចយើងភ្នុកភ្លើងយើងអង្គុយអាំងអីចឹងណា ចាសយើងដុតភ្លើងពីលើណឹងឯងទៅមើលតែយូរអស់ចិត្តអស់ថ្លើមមើលតែគេទៅអស់ស្វាត់ចឹងទៅ បានយើងបុសអាភ្នុកភ្លើងណឹងចេញទៅ កាយអាដីណឹងយើងលើកអាកូនឆ្នាំងណឹងមកសម្លរឆ្អិនដែរ បាយក៏អញ្ចឹងដែរអ្នកគ្រូពេលណាខ្ញុំលួចបូតខ្ញុំនិយាយអស់កេរ្តិ៍ម៉ង យើងលួចបូតស្រូវគេបានចឹងទៅខ្ញុំឡើងទៅលើចុងអំពិល ខ្ញុំឡើងទៅលើចុងអំពិល ដើមអំពិលណឹងវាធំចឹងទៅវាបែកមែកសាខាសងខាងចឹងទៅ កាប្រឡោះ កណ្តាលណឹងវាមានដូចយើងអញ្ចឹងចឹងទៅក្រឡុកចឹងទៅខ្ញុំខែៗ

កាំបិត ខែៗឲ្យរាងជ្រៅឲ្យក្រឡុកបានប៉ុណ្ណឹងចឹងទៅ យើងដាក់ទ្រាប់ស្អីគេដូចត្បាល់ទៅ បុកស្រូវ បុកអង្ករស្រូវយើងណឹងឯងគេអត់លី ចាសដើមអំពិលណឹងវាខ្ពស់ចឹងទៅគេនៅឆ្ងាយៗចឹងទៅយើងបុកអត់លី ចាសដល់ពេលបុករួចចឹងទៅ មើលថាយើងបូតប៉ុណ្ណឹងឯងចឹងណាអ្នក គ្រូ ចឹងហើយយើងចុកអត់ចឹងអីទៅយើងអត់ហ៊ានអ៊ុំ អត់ហ៊ានផ្លុំអីលើណឹងទេចាសក្រប៉ាត់មួយប៉ុណ្ណេះ ចុះមកចឹងទៅ ហើយមានដំបូកធំៗស្អុកៗអីចឹងទៅ យើងអត់ហ៊ានឆ្ការទេអាពីក្រៅទោះបីបន្លារយ៉ាងណាក៏ដោយ វែកៗចូលតែមួយខ្លួនចឹងទៅយើងទាញ បិទៗចេះមកវិញ ចាសទៅយើងវែកៗតែអាក្នុងណឹងឲ្យរាងស្រឡះឲ្យយើងអង្គុយបានចឹងទៅ អ៊ុំស្រូវនៅក្នុងណឹងឯង ចាសយកមកឲ្យមីប្អូននេះស៊ីនិងម្ដាយចាស់ ខ្លួនខ្ញុំសុទ្ធចិត្តដើរទៅ ទៅអញ្ចេះទៅ ស្លឹកឈើអីក៏ហូបដែរអ្នកគ្រូឲ្យតែហូបកើត ចេះតែថាធ្វើម៉េចឲ្យតែបានដូចថាបានធូន់ពោះរចឹងទៅ ២ ៣ម៉ាត់ចឹងទៅយើងផឹកទឹកចឹងទៅយើងធូន់ពោះរ បើបាយបបរគេមក មួយឆ្នាំធំប៉ុណ្ណឹងចឹងមកសារិតព្រលិតអស់ចឹងទៅចាក់ទឹកអស់នៅកូនគ្រាប់អង្ករបានរមួយកូនវែកប៉ុណ្ណឹង ហើយបើថាឃើញផ្ទះណាដែលមាន ភ្លើងហ៊ុយ ចាសមកដល់ដឹងតែងាប់ហើយឲ្យតែគេឃើញ គេអត់ឲ្យយើងធ្វើអីទេ ចាសត្រីដែលវារកបានអញ្ចឹងមកដែលគេធ្វើស្លរដាក់ក្នុងផ្ទះបាយដាក់បបរចឹង គេបបរឲ្យយើងគេបបរលាយព្រលិតគេស្លរម្ជូរត្រកួនអីចឹងណា វាកាត់ក្បាលត្រីចោលអីចឹងទៅ យកទៅចាក់ចោលនិងជ្រាំ និងក្រឡុកអីចឹងទៅប្អូនខ្ញុំមីនេះ វាឃើញចឹងទៅវាឃ្លានវាក្បាលត្រីដែលនៅស្រស់ៗដែលទើបតែធ្វើរួចចឹងទៅ គ្នាទៅរើសមកចឹងទៅវាផ្ដាច់អត់ឲ្យបបរ អត់ឲ្យអីទេវាឲ្យអត់បាយថ្ងៃណឹងមួយថ្ងៃ របបវាអត់ឲ្យទេ ហើយវាឲ្យទៅឈរហាលថ្ងៃមួយថ្ងៃចឹងទៅ ហើយប្រធានសហករណ៍គេនោះ ឈ្មោះទៀង ប្ដីគេនោះឈ្មោះអាប៉ិស្រ៊ុន ចាសហើយថាវេទនណាណាស់អ្នកគ្រូអើយ ហើយប្អូនខ្ញុំមីមួយនេះ មីទី៣នេះជើងនេះហើមប៉ុណ្ណេះជើងហើមស្ពីញ ហើយខ្ញុំកុហកគេមើលទៅស្រណោះប្អូនពេក ចាសខ្ញុំកុហកគេសុំប្រធានសហករណ៍គេយកប្អូនមកនៅជាមួយអីចឹងមក កុហកប្អូនថាដូចថាមិត្តបងអើយខ្ញុំសុំប្អូនឲ្យមកនៅជាមួយម្ដា

យចាស់អីចឹងណា ហើយឲ្យប្អូនទៅនៅជាមួយបងស្រីចឹងទៅ បងស្រីទៅនៅខាងចល័តចឹង ប្អូនខ្ញុំណឹងវាស្គន់ជាន់ កុហាកគេចឹងទៅគេជឿអ្នកគ្រូទៅគេជឿដែលឃើញជើងដែលវាអត់ បាយអត់អីចឹងទៅវារដើរវាគ្មានកម្លាំងនោះ ចាប់ដើរទៅវាជំពប់ជើងចឹងទៅវារបើកអាក្រចកទៅ ក៏វាហើមទៅដល់ខាងណោះចឹងណា ចាសដល់ពេលនេះទៅខ្ញុំស្រណោះប្អូនពេកចុះយើងនៅ ចល័តយើងប្រើ បាយមួយកូនវែកប៉ុនៗណឹងគេប្រើវ៉ាល់ៗល្ងាច រើសអង្ករស្រូវទៅអីទៅ តាមតែ វាប្រើតាមអំពើចិត្តអ្នកគ្រូបើយើងមិនទៅមានតែយកយើងទៅសម្លាប់ចោល ហើយអ្នកដែល នៅណឹង មួយក្នុងកងចល័តណឹងអ្នកគ្រូអើយអាខ្លះក៏ទទូរភ្លួយ ចឹងទៅក៏ដេកងាប់ទៅ អត់រឿង ចឹងទៅដែលវាដូចថាអត់បាយអត់អីចឹងគ្នាអត់មានអីហូបគ្រប់គ្រាន់ចឹងទៅវា រវើយទៅមិនរួច ទៅទៅជាគ្រុនទៅជាអីទៅណា ចាសចឹងទៅក៏ទទូរភ្លួយដេកចឹងទៅក៏ងាប់ទៅ ទៅប្អូនខ្ញុំខ្លាច ខ្មោចវាយំអើយយំ ទៅក៏ខ្ញុំមិនដឹងធ្វើយ៉ាងម៉េចប្រើល្បិច ខ្ញុំប្រាប់ម៉ែខ្ញុំថាម៉ែៗបើប្រធានសហករ ណ៍គេសួរម៉ែឯង ម៉ែឯងកុំឲ្យធ្វើមាត់ណាបើសិនជាគេសួរថាមីហ្នឹងវានៃស្គាន់ជាន់ម៉ែឯងចាំប្រាប់ ថាគេថាស្គាន់ជាន់តាមខ្ញុំណាម៉ែឌ្យិបប្រាប់ម្តាយចេះឯង ម៉ែខ្ញុំគាត់ខ្លាចគេឡើងញ័រចាសដល់ ពេលនេះទៅគាត់ថាដឹងណាកូនឯងកូនអើយកុហាកគេប្រយ័ត្នគេតាមដានទាន់គេយកកូនឯង ទៅសម្លាប់ ខ្ញុំកាលណឹងហៅតែអាយុ១៨ឆ្នាំមែនអ្នកគ្រូក៏ប៉ុន្តែខ្ញុំតូចមែនទែន ចាសខ្ញុំមាឌតូច ណាស់ គ្មានអ្នកណាគេជឿថាខ្ញុំអាយុ១៨ឆ្នាំ ១៩ឆ្នាំអីទេ គេអត់ជឿខ្ញុំទេ គេឯងគេយកចូល ចល័តប្អូនខ្ញុំគេយកចូលចល័តខ្ញុំគឺនៅដាក់នៅកុមារអាចម៍គោ វាទៅអញ្ចឹងណា ចាសចុះខ្ញុំតូច មែនទែនណា អញ្ចឹងទៅខ្ញុំប្រាប់ម៉ែខ្ញុំចឹងម៉ែខ្ញុំថាកូនអើយកុហាកគេណាកូនប្រយ័ត្នគេតាមដាន កូនអើយសព្វថ្ងៃគេថ្ងៃគេអង្គការភ្នែកម្នាស់កូនស្រីម្តាយ យំផងអីផង ម៉ែឯងកុំនេះប៉ុន្តែម៉ែឯងកុំ ឲ្យតែមាត់ទៅ យើងផ្សងប្រងទៅម៉ែអាណិតប្អូនវាខ្លាចខ្មោចផងណាវាឃ្លានបាយផង ហើយ ណាវាឈឺជើងទៀតហើយប្អូនខ្ញុំទី៣នេះស្តេច ស្តេចខ្លាចគេណាស់លោកគ្រូហើយក៏គ្រង់ស្លូត កាលណឹងវាខ្លាចគេណាស់ ទៅខ្ញុំស្រណោះវាពេកវាសុំគេ ទៅខ្ញុំទៅសុំប្រធានសហករណ៍ថា

មិត្តបងអើយមិត្តបង មិត្តអុំ មិត្តឮ អីចឹងទៅណា ចាសខ្ញុំសុំយកប្អូនខ្ញុំមកព្រោះប្អូនខ្ញុំមើលព្រោះ ពាគវាស្អាន់ជាន់ ដល់ពេលនេះទៅមើលសំណាងហើយវាប្រកាច់លើគោកវាអត់ងាប់ វាគ្រាន់តែ បែកក្រចកជើងក្រចកដៃអីចឹងណា ចាសប្រសិនជាថ្ងៃណានេះទៅវាប្រកាច់ក្នុងទឹកក្នុងអីទៅ ប្អូនខ្ញុំដឹងតែថាងាប់ខ្ញុំសុំឲ្យវាមកនៅជុំជាមួយម៉ែខ្ញុំដែលចាស់នេះមក ដល់ចឹងក៏ត្អូរត្អែរយំអីផង ចឹងទៅ ប្រធានសហករណ៍ណឹងគេស្រណោះចាសគេស្រណោះខ្ញុំ គេឲ្យគេស្នើរសុំដកមីប្អូនខ្ញុំ មីទី៣នេះឯងយកមកនៅជាមួយម៉ែ នៅបានប្រហែលមួយខែ គេបញ្ជូនមកទាំងបងទាំងប្អូន ចាសគេដកពីស្រែបឹងឈូកណឹងមកគេយកមកដាក់ណឹងរោងម៉ាស៊ីនកន្លែងចល័តគេណឹង រោងម៉ាស៊ីនអូរតាគីគេហៅរោងម៉ាស៊ីនអូរតាគីយើងណាអ្នកគ្រូ ចាសទៅខ្ញុំមិនដឹងគិតធ្វើយ៉ាង ម៉េចទេ អនាគតម្ដាយ ម្ដាយចាស់នៅតែ២នាក់ប្អូនខ្ញុំមីពៅនេះវានៅតូចញីប ម៉ែអញដឹងតែងាប់ ហើយដាច់ខាចដឹងតែងាប់ហើយខ្ញុំ ពិគ្រោះគ្នា២នាក់បងប្អូនមីទី២នេះឯងអាប្រុសមួយគេនៅ ជាមួយបងស្រីគេឯណោះ ទៅពិគ្រោះអ្នក២នាក់បងប្អូននាងហ្បរយើងគិតរត់ហើយណាអូន ខ្ញុំ ថាចឹងឯងចៃអើយប្អូនខ្លាច ថាអូនឯងមិនបាច់ខ្លាចទេមានបងហើយ ហើយខ្ញុំអ្នកគ្រូខ្ញុំនិយាយ កាលប្រវិត្ត ណឹងខ្ញុំចង់តែយំទេ ខ្ញុំមានសំឡុយម៉ែខ្ញុំមួយម្ដាយឲ្យសំឡុយមួយ ទៅខ្ញុំនាំបងប្អូន រត់ហើយរត់មិនមែនរត់តែខ្លួនទេ ខ្ញុំនិយាយឲ្យអស់កេរ្តិ៍ លួចបាយ បានមួយកូនផ្តិលប៉ុននេះបង ភាព បាយកូនផ្តិលប៉ុននេះរកអីដាក់មិនបានទេ បានកូនផ្តិលគេប៉ុននេះមួយដាក់បាយឡើង ពេញ មើលទៅនៃ គ្រូបង្រៀនគេគ្រូចល័តគេណឹងគេដេកលក់ចឹងទៅ លួចកើបអង្ករនោះបាន ប្រហែលជា១០កំប៉ុងចុះយកទៅផ្ញើម្ដាយ ខ្ញុំបាយមួយផ្តិល អង្ករនោះ១០កំប៉ុងប្រហែលមិន ដល់ទេប៉ុនតែថា១០ចុះ ចាសវិចនិងអាវ អាវកាលនោះអាអាវខ្មៅគេជ្រលក់នោះវិចណឹងអាវ ចេះឯងទៅចង់ភ្ជាប់ក្រវ៉ាត់និងចង្កេះ ចាសបាយណឹង កន្សែងមួយណឹងចងនិងផ្តិលបាយណឹ ងស្ពាយ ដៃមួយចំហៀងដើរដឹកដៃប្អូនប៉ុន្តែប្អូនមែនក៏ប៉ុន្តែប្អូនខ្ញុំមីនេះវាមាឌធំជាងខ្ញុំ ដៃមួយ ចំហៀងដឹកដៃប្អូន ដឹកដៃប្អូនមួយចំហៀងដើរនឹកឃើញអស់ហើយគុណម៉ែគុណឪជួយកូន

ហើយរត់កាត់ណាអ្នកគ្រូស្វាត់ឈឹងទំនប់ក្រពឹងពួងគេនេះ ទំនប់ចេះពីអូរតាគីទៅទំនប់គេអញ្ចឹងណា ចាសទំនប់គេអញ្ចឹងឯងស្វាត់ឈឹងហើយព្រៃវាដុះឡើងស្លុបសងខាង ទៅអស់ហើយខ្ញុំអត់មាននឹកអីអ្នកគ្រូវគ្គណឹងអត់មាននឹកអីទាំងអស់ឲ្យក៏ស្វាត់ឈឹងយប់ម៉ោង១២យប់ខ្ញុំរត់នាំប្អូនរត់ គុណម៉ែគុណឪជួយកូនឲ្យដើរចឹងទៅអ្នកគ្រូអើយហ្វូងឆ្កែចចក ចុះវាយំចឹងទៅ មើលទៅទាំងហ្វូងចឹងឯងទៅអ្នកគ្រូអើយ ខ្ញុំក្រាបភ្លឹប ក្រាបភ្លឹបប្អូនអត់មានម្ដាយមីងអត់មានអីនេះទេសំឡុយម្ដាយទទូរដាក់ប្អូនពីក្រោមទ្រូងអញ្ចេះហើយទៅទទូរសំឡុយម៉ែខ្ញុំគុណម៉ែគុណឪជួយកូន គុណម៉ែគុណឪជួយកូន មើលវាទៅផុតបាត់ប្រហែលជាស្វាត់មាត់វាយំចឹងនាំបងប្អូនរត់ទៅទៀតហើយ រត់ទាល់តែដល់ម្ដាយភ្លឺច្បាស់បានដល់ម៉ែខ្ញុំនៅឯបឹងឈូក ទៅដល់ថ្ងៃណឹងល្ងាណឹងប្រធានសហាករណ៍គេទៅតាមអ្នកគ្រូអើយគេប្រមាថយកទៅបាញ់ចោលបាញ់អីគេយកខ្សែយកអីមកចងខ្ញុំប៉ែយខ្ញុំលេងប៉ាហ៊ីចឹងអ្នកគ្រូ ខ្ញុំប្រាប់ថាមិត្តបងបើខ្ញុំអត់ប្រកែកប្រណាំងទេបើយកខ្ញុំទៅខ្ញុំទៅបញ្ជូនខ្ញុំទៅខ្ញុំទៅក៏ប៉ុន្តែ សុំមិត្តបងអាណិតស្រណោះខ្ញុំផងយកម៉ែខ្ញុំទៅផងបានខ្ញុំទៅបើថាមិនអញ្ចឹងទេ មិត្តបងសម្លាប់មិត្តអ៊ុំ មិត្តពូ សម្លាប់ខ្ញុំទាំងម៉ែទាំងកូនទាំងអស់នេះទៅ ឲ្យខ្ញុំទៅចោលម៉ែខ្ញុំអត់ទៅទេម៉ែខ្ញុំចាស់ហើយ ណាមួយប្អូនស្គាន់ជាន់ណាមួយប្អូនតូចចេះតែរាប់រៀបយំអោបជើងគេអីចឹងទៅ លោកគ្រូគេប៉ុន្តែកាលណឹងដូចថាគេអាណិតស្រណោះខ្ញុំអញ្ចឹងគេឲ្យទាំងម៉ែខ្ញុំមកដែរ ដល់រៀបវៀតណាមវាយដាច់នេះលោកគ្រូខ្ញុំថាម៉ែខ្ញុំស្លាប់ពេល ណឹងហើយ ថាម៉ែខ្ញុំងាប់ពេលណឹងវាចងក្រពាត់ស្លាបសេករួចអស់ហើយ វាហៅម៉ែខ្ញុំដាក់រទេះហើយណឹងណា ចាសបររទេះចេញរទេះបរហើយដាក់ត្នែកទៅលើថ្នល់ចេះខ្ញុំឃើញពួកចល័ត ចល័តនៅរោងម៉ាស៊ីនដើមស្រល់ណឹង ចាសខ្លះទូលកញ្ជើរ ខ្លះទូលចង្អេរខ្លះមានប្រវិចកន្សែង ខ្លះមានអីចឹងណាចុះស្រូមកខ្ញុំចេញទៅដល់ឈរកាក់កណ្ដាលផ្លូវចេះថ្នល់គេអញ្ចេះឯងផ្លូវរទេះគេ ទៅដល់សួរគេមិត្តបង មិត្តបងចុះនាំគ្នាទៅណាគេបរទេះម៉ែខ្ញុំយកទៅអញ្ចេះបាត់ហើយ ចាសចុះយើងរទេះគោអ្នកគ្រូ គោវាដើរត្រឹក ១១១ចេះឯងបានប្រហែល

ជាជិតពីនេះទៅថ្មល់ហើយណឹងណា ចេញពីអាកន្លែងខ្ទមដែលវាឲ្យយើងនៅណឹងណា ចាស ទៅខ្ញុំសួរចឹងឯង សួរថាមិត្តបងមិត្តបងណែ មិត្តបងនាំគ្នាទៅឯណា ស្រូស្រមានកញ្ជើរមានអ្នកចង្អេរ សួរគេអញ្ចឹងនោះ ចាសដល់នេះទៅគេប្រាប់ថាមិត្តអូននៃកុំខ្លាចអីទៀតនៃទ័ព្វលោកច័ន្ទរង្សីចូលមករំដោះយើងហើយនោះអូនឯងអើតមើលសុទ្ធតែរថក្រោះ ចាសខ្ញុំស្រែកបណ្ដោយខ្ញុំស្រែកហៅបងខ្ញុំ បងជីដូនមួយជីដូនអីដែលអ្នកនៅជិតខាងអីចឹងណាខ្ញុំថាបងៗអើយទាំងអស់គ្នា នៃទ័ព្វលោកច័ន្ទរង្សីចូលមករំដោះយើងហើយគេឲ្យទៅយកអង្ករយកអីកន្លែងរោងម៉ាស៊ីនស៊ីក៏ផ្អើលឈូទៅអញ្ចេះឯងទៅក៏បងខ្ញុំ ទាញខ្វារថាទៅរកកាប់អាតាប៉ិសហាករណ៍ អាប៉ិស្រ៊ុនណឹងឯងដែលវាយកម៉ែខ្ញុំទៅសម្លាប់នោះទៅក៏ អានោះវារត់ទៅកាលណាបាត់សូន្យម៉ែឯងក៏នៅជាប់ចំណងចេះឯងទម្រាំបានឯងរត់ទៅដល់ស្រាយម្ដាយ បងអើយអាសូរតែថាគេឲ្យយើងយកអង្ករយកអីស៊ីចឹងណាហើយរទេះគេទឹមគោស្រេច អាសូតែនាំបងប្អូនឡើងរទេះណឹងបរទៅអត់ អត់ទេល្ងង់អីម្ល៉េះ អាគោ អារទេះហ្អែងនៅឯណានៅទៅស្រាយតែចំណងម្ដាយរួចក៏អោបម្ដាយដឹកម្ដាយមកក៏នាំម្ដាយទៅយកអង្ករនិងគេស៊ី អាគោនោះក៏នៅចោលដោយរទេះហើយត្រូវអាអ្នកប្រុសៗ ពួកអ្នកជិតខាងបងជីដូនមួយជីដូនអីដែលគេបញ្ជូនទៅជុំណឹងណា វាអត់មានថាទៅចង់បានគោយករទេះណឹងទៅដឹកអង្ករដឹកអីអត់អ្នកគ្រូឯងមើល សុខចិត្តទៅនាំគ្នាស្ពាយម្នាក់បានមួយបង្វេចទៅឯងនេះក៏បានមួយបង្វេចទៅអីទៅ អាណារត់ទៅតាមបងនៅឯស្រែទួលចារនោះទៀតនេះបងស្រីនេះ ហើយពីយើងពីអូរតាគីពីស្រែបឹងឈូកណឹងទៅស្រែទួលចារណឹងមិនជិតទេអ្នកគ្រូ ប្រហែលពីនេះយើងទៅស្ពានក្រវ៉ាត់ក្រុងអីនោះអស់ជិតហើយប៉ុណ្ណឹង ចាសខ្ញុំរត់ យីកាលណឹងរត់អត់ហាត់ទេដែលវាអរណាស់ពេក អូយ វេទនាណាស់លោកគ្រូអើយនិយាយពីប្រវិត្តណឹងថា និយាយពីម៉ោងនេះដល់យប់មិនអស់ទេ សង្ឃឹមឪពុកឡើងមកពីនេះដល់ចូលវៀតណាមគេចុះដល់ព្រែកទាល់ព្រែកអីនេះគេវាយបានសម្រេចហើយឪពុកឡើងទៅហើមឆ្អឹងជំនីរមួយចំហៀងទៀត ដែលគាត់នេះទៅវាវាយ កុំអីប៉ុន្តែថាដូចអាយុ

គាត់ដូចអត់ត្រូវអស់ចឹង ប៉ាខ្ញុំគេចងវាយឡើងឆ្អឹងជំនីរនេះមួយចំហៀងឡើងប៉ោងហើយថា ងាប់ហើយ ចេះអត់ងាប់ដែរដល់វៀតណាមចូលមកវាមានអីវារត់ខ្លួនវាទៅយើងវានៅចោលណឹងឯង យើងអត់ទាន់បានងាប់ផងណឹងក៏រស់បានទាំងឪពុកទាំងម្ដាយណឹងឯង ទើបតែគាត់មកអស់បុណ្យនិងយើងសម័យយើងនេះឯងទេ កុំអីនោះថាវេទនាណាស់ខ្ញុំវាវេទនារកអីមកប្រៀបមិនបានទេណា បានថាសព្វថ្ងៃប្រាប់កូន ប្រាប់ចៅ ថាកូនឯងសព្វថ្ងៃសំបូរសប្បាយណាស់ កូនកុំបើកូនឯងកើតទាន់ប្រវិត្តម្ដាយណាកូនបានថាដល់អានោះបានកូនឯងសប្បាយមែនទែន ស្រុកគេសប្បូរសប្បាយប៉ុននេះហើយកូនឯងកុំដើរផ្លូវខុសឲ្យសោះ ព្រោះប្រវិត្តម្ដាយវាឆ្អែតឆ្អន់អស់ហើយ ហើយរាល់ថ្ងៃអ្នកគ្រូមិននិយាយថាយ៉ាងម៉េចទេខ្ញុំពីដើមមិញដូចជានឹកឃើញថាអ្នកខ្លះគេនិយាយគេថាគេថាចេះណា ឪព្រះអង្គអើយខ្ញុំនិយាយនេះខ្លះគេថាហ៊ុន សែនជាប់គ្រប់អណ្ដិតក៏ប៉ុន្តែហ៊ុន សែនជាប់ណឹងបានជាយួននៅពេញស្រុកពេញភូមិ ខ្ញុំពីដើមមិញមែននឹកឃើញដូចជឿតាមគេអញ្ចឹងណា ប៉ុន្តែដល់សព្វថ្ងៃអត់ទេអ្នកគ្រូ ខ្ញុំនឹកឃើញថាអរបើតាមពួកនេះឆ្កួតទេ បើនិយាយថាខូចពីហ៊ុន សែនបានយួននៅពេញស្រុកពេញភូមិ យើងបើសិនជានិយយាថាកុំឲ្យតែយួននេះក៏យើងអត់បានមានជីវិតដល់សព្វថ្ងៃ បើគ្មានហ៊ុន សែនក៏ខ្ញុំរាល់មិនថាខ្ញុំមិនថាគេទេបែបជាងាប់អស់ក៏មិនដឹង អញ្ចឹងណាបានថាខ្ញុំនឹកឃើញចិត្តមួយថាកុំភ្លេចគុណហ៊ុន សែន លោកជួយណាស់បើកុំតែបានលោកជួយនេះក៏យើងមិនដឹងទៅជាស្អីទេ ហើយក៏គ្មានថ្ងៃនេះដែរខ្ញុំចង់និយាយអញ្ចេះម៉ង បានថាខ្លះអ្នកដែលថាខឹងនិងហ៊ុន សែន មានបើកច្បាប់ឲ្យយួនចូលមកប្រទេសខ្មែរកុំឲ្យខឹងនិងគាត់ បើកុំឲ្យបានគុណគាត់ណឹងយើងគ្មានថ្ងៃនេះទេ ខ្ញុំចង់និយាយអញ្ចឹងឯង បានថាប៉ុណ្ណឹងសិនបានហើយដឹងអ្នកគ្រូ។

កៈ បាទចុះម្ដាយរបស់អ៊ុំមានឈ្មោះអ្វីដែរអ៊ុំ?

ខៈ ចាស ម៉ាក់ខ្ញុំឈ្មោះស្រស់ ហាង។

កៈ ស្រស់ អាន?

ខៈ ស្រស់ ហាង។

កៈ ស្រស់ ហាន។

ខៈ ហាង ហាងលក់ឥវ៉ាន់។

កៈ អរបាទ ចុះគាត់មានស្រុកកំណើតនៅឯណាដែរអ៊ុំ។

ខៈ ម៉ែខ្ញុំនៅស្រុកនេះឯង បើប៉ាខ្ញុំ បានអ្នកស្រុកព្រៃកទាល់។

កៈ ឪពុកឈ្មោះអ្វីដែរអ៊ុំ?

ខៈ ប៉ាខ្ញុំឈ្មោះកោយ គាត។

កៈ ចុះពួកគាត់ទាំងពីរនាក់ណឹងជាមនុស្សបែបណាដែរអ៊ុំ? ជាមនុស្សកាច ឬក៏ស្លូតដែរ?

ខៈ ទេបើប៉ាខ្ញុំស្លូត ប៉ាខ្ញុំបួសជវស្សាចាសប៉ាខ្ញុំស្លូតណាស់ ចាសបើម៉ែខ្ញុំរាងកាចតិចតែគាត់កាចនិងកូនចៅទេ កាចតែនិងកូនបើញាតិសន្តានអីម៉ែខ្ញុំមិនដែលទេនៅត្រង់ណាមិនដែលចេះឈ្លោះនិងគេផង។

កៈ ចុះពួកគាត់ទាំងពីរណឹងប្រកបការងារអ្វីដែរដើម្បីចិញ្ចឹមជីវិត?

ខៈ ម៉ែប៉ាខ្ញុំពីដើមមិញមកគាត់ ប៉ាខ្ញុំគាត់វាយមោងដាក់លបដាក់អីណឹងឯង ចាសបើម៉ែខ្ញុំមិនដែលទៅណាទេនៅតែធ្វើអ្នកស្រីនៅតែផ្ទះ មិនដែលធ្វើអីគាត់។

កៈ ចុះឪពុកម្ដាយរបស់អ៊ុំធ្លាប់ប្រាប់ប្រវិត្តរបស់គាត់មកកាន់អ៊ុំទេថាគាត់ កាលស្រលាញ់គ្នាម៉េច? ឬក៏កាលនៅក្មេងម៉េចដែរ?

ខៈ អត់ផង គាត់មិនដែលនិយាយអីផង ប៉ុន្តែថាប្ដីប្រពន្ធគាត់ចាប់តាំងពីខ្ញុំចាប់ធំដឹងក្ដីមកមិនដែលឃើញម៉ែប៉ាខ្ញុំចេះទាស់គ្នាទេខ្ញុំនិយាយតាមត្រង់ មិនដែលថាម៉ែខ្ញុំទាស់គ្នាឲ្យថាឲ្យលឺដល់ញាតិជិតខាងសូម្បីតែកូនធំៗនៅក្នុងផ្ទះ ចាសតាំងពីខ្ញុំធំដឹងក្ដីខ្ញុំមិនដែលឃើញម៉ែខ្ញុំទាស់គ្នាផង ប៉ុន្តែខ្ញុំឆ្លាតទៀតខ្ញុំចំណាំ ចំណាំថាបើលើកបាយចឹងមក ម៉ែប៉ាពិសារបាយទៅគាត់បញ្ជូនគ្នាហើយ គាត់ថាទៅហៅប៉ាង៉ែងហូបមុនទៅ ហៅប៉ា ប៉ាពិសារបាយប៉ា អរហៅម៉ែង៉ែងចឹងប្រអប់ថ្នាំមួយម្នាក់មួយទៅខាងណោះមួយទៅខាងណោះខ្ញុំដឹងហើយ ដឹងថាម៉ែប៉ាខ្ញុំទាស់គ្នាបើគាត់អត់ទាស់គ្នាគាត់អត់ដែលចឹងទេ បើថាពេលបាយចឹងទៅមកបងអើយកូនលើកបាយមកហើយចឹងឯង ជូនកាលទៅប៉ាខ្ញុំម៉ែអានាងមកបាយកូនលើកមកហើយចឹង បើថាគាត់ឈ្លោះគ្នាគាត់បញ្ជូនគ្នា ហៅប៉ាង៉ែងទៅ ហៅប៉ា ប៉ាថាហៅម៉ែង៉ែងទៅចឹងឯង ចឹងខ្ញុំដឹងថាគាត់ឈ្លោះគ្នា ហើយកូនចៅគឺត្រៀមរកគៀនជញ្ជាំងគៀនអីឲ្យហើយស្ងាត់ៗពីគាត់ទៅតាមតែគាត់គ្នាគាត់ទៅ ហើយគាត់អត់ដែលចេះឈ្លោះគ្នាឲ្យកូនណាលឺទេ បើថាគាត់ឆាំងសម្ដីគ្នា ម្នាក់កញ្ចុបទៅណោះ ម្នាក់កញ្ចុបទៅណោះខ្នងទល់គ្នាមកុំ

កៈ ចុះអ៊ុំនៅចាំឈ្មោះជីដូនជីតាបានទេអ៊ុំ? យាយតាខាងម្ដាយឈ្មោះអ្វីដែរអ៊ុំ?

ខៈ ខ្ញុំចាំតែឈ្មោះយាយ តែមិនដឹងថាគាត់នាមត្រកូលអី ខ្ញុំអត់ដឹងដែរ យាយខ្ញុំឈ្មោះយាយលឹម។

កៈ យាយលឹមណឹងយាយរបស់ម្ដាយអ៊ុំ?

ខៈ ចាស។

កៈ ចុះតាចាំទេ?

ខៈ បើនិយាយទៅតួតម៉ង តួតឈ្មោះតួតស្រស់ តួតប្រុស ចាសចឹងបានម៉ែខ្ញុំដាក់ឈ្មោះតាគាត់ដាក់ស្រស់ ហាង បើយាយខាងប៉ាឈ្មោះយាយហោង។

កៈ ចុះតាវិញ?

ខៈ តា ឈ្មោះតាកោយ។

កៈ តាកោយ យាយហោង?

ខៈ ចាស។

កៈ ចុះកាលដែលអ៊ុំកើតមកណឹងអ៊ុំកើតទាន់ពួកគាត់ទាំង៤នាក់ទេ?

ខៈ អត់ផង យាយខ្ញុំបង្កើតកើតអត់ទាន់ផង ទាន់តែបងស្រីមួយ។

កៈ អរ អត់ទាន់ទេ អត់ដែលឃើញមុខយាយតាទេ?

ខៈ អត់ អត់ដែលឃើញ ឃើញតែក្នុងរូបថត។

កៈ បាទ ចុះពួកគាត់ទាំង៤នាក់ណឹងប្រហែលជាមានស្រុកកំណាតើនៅជាមួយគ្នាដែរមែនអ៊ុំ?

ខៈ ចាស បើយាយខាងម៉ែខ្ញុំ តាខាងម៉ែខ្ញុំពូជអំបូរខាងម៉ែខ្ញុំអ្នកស្រុកណឹងម៉ង ចាសបើប៉ាខ្ញុំគាត់អ្នកព្រែកទាល់ ដល់ពេលគាត់បានម៉ែខ្ញុំអីមកគាត់មកនៅឯណោះឯងនៅស្រុកនេះឯងដែរ ប៉ុន្តែគាត់នៅរហូតទាំងបងប្អូនអី ជីដូនមួយ ជីដូនពីរ មកនៅឯណោះឯងទាំងអស់គ្នា។

កៈ ចុះអ៊ុំមានបងប្អូន ឬក៏សាច់ញាតិដែលរស់នៅក្រៅប្រទេសអត់ទេអ៊ុំ?

ខ៖ អត់អ្នកគ្រូ។

ក៖ អត់មានទេ?

ខ៖ អត់។

ក៖ បាទ។

ខ៖ មានតែបងជីដូនមួយមួយ បងជីដូនមួយណឹងគាត់បាត់ឈ្មោះកាលជំនាន់ប៉ុល ពត គេបញ្ជូនទៅជុំជាមួយពួកខ្ញុំណឹងឯងក៏ប៉ុន្តែគាត់បាត់ ដល់វៀតណាមវាយដាច់មកអត់ឃើញគាត់មកសោះ មិនដឹងថាគាត់រស់ ឬមួយគាត់ស្លាប់ ឬមួយគាត់ថាគាត់នៅរស់មិនដឹងជាគាត់ទៅខាងណាអត់ដឹងដែរ បាត់រហូតដល់សព្វថ្ងៃ ចាសបងប្រុសនោះឈ្មោះឃុន ចាសមានសុឃុន ចាសបាត់ឈ្មោះដល់សព្វថ្ងៃឪពុកគាត់ឈ្មោះមាន។

ក៖ ចុះស្វាមីរបស់អ៊ុំមានឈ្មោះអ្វីដែរអ៊ុំ?

ខ៖ ឈ្មោះរុន។

ក៖ ត្រកូលអ្វីដែរអ៊ុំ?

ខ៖ យន់ សារុន។

ក៖ ចឹងអ៊ុំបានរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីណឹងប៉ុន្មានឆ្នាំហើយអ៊ុំ?

ខ៖ យូរដែរហើយលោកគ្រូ ប៉ុន្មានឆ្នាំហើយចូល៤ ១០ ២០ឆ្នាំ ៣០ឆ្នាំហើយដឹង។

ក៖ កូនបងគេអ៊ុំអាយុប៉ុន្មានហើយ?

ខ៖ ចាស?

ក៖ កូនបងរបស់អ៊ុំ?

ខ៖ ចាស ៣០ជាងហើយលោកគ្រូ។

ក៖ ចឹងការបាន៣០ឆ្នាំជាងហើយ។

ខ៖ ចាស។

ក៖ ចុះអាពាហ៍ពិពាហ៍អ៊ុំណឹងត្រូវបានរៀបចំឡើងដោយឪពុកម្ដាយ ឬក៏រៀបចំឡើងដោយចិត្តខ្លួនឯងដែរអ៊ុំ?

ខ៖ ម៉ែប៉ាឲ្យ។

ក៖ ចុះប្ដីរបស់អ៊ុំណឹងជាអ្នកនៅស្រុកនេះដែរមែន?

ខ៖ អត់ទេគាត់អ្នកបាត់ដំបង គាត់អ្នកម៉ោង។

ក៖ អ្នកស្រុកម៉ោង?

ខ៖ ចាស។

ក៖ ចុះអ៊ុំហេតុអីក៏ស្គាល់គ្នាជាមួយគាត់ដែរអ៊ុំ?

ខ៖ គាត់មក គាត់ធ្វើទាហាន គាត់ធ្វើទាហានមកក៏ថាដូចជាឃើញគ្នាទៅ សួរទៅក៏ម៉ែខ្ញុំឲ្យប៉ាខ្ញុំគាត់ឲ្យ ចាស់ៗគេរៀបឲ្យទៅ។

ក៖ ចឹងមានន័យថាគាត់អ្នកបាត់ដំបង គាត់មកធ្វើទាហាននៅនេះ?

ខ៖ ចាស។

ក៖ ចុះអ៊ុំមានអនុស្សាវរីយ៍អ្វីខ្លះដែរជាមួយស្វាមីណឹងណា ពីមុនរៀបការមួយគ្នា ស្គាល់គ្នាម៉េចដែរ? ឬក៏គាត់ទាក់ទងជាមួយអ៊ុំម៉េចដែរ?

ខ៖ មិនដែលមានផងលោកគ្រូ គាត់ស្គាល់ខ្ញុំគាត់សួរម៉ែខ្ញុំបណ្ដោយខ្ញុំមិនដែលមានអីផង មិនដែលបានប្រាប់ដូចឧបមាថាស្រលាញ់គ្នាជួបគ្នាអីអត់។

ក៖ អត់ធ្លាប់បានទៅដើរលេង ដើរអីជាមួយគ្នាអត់ទេ?

ខ៖ ដើរលេងឯណាកាលណឹងវត់អាស្មីនេះនោះ អាសម័យរាស្រ្តនិយមនោះ នៅអាពត នៅទាហានយួន ទាហានខ្មែរយើងនោះ ចាសនៅសង្គ្រាមនៅឡើយនោះចាស ទៅហ៊ានទៅឯណាម៉ែប៉ាណាមិនដែលឲ្យទៅណាផងមិនដែលហ៊ានបានដើរទៅណា។

ក៖ បាទអ៊ុំ ចុះកាលណឹងអ៊ុំចាំទេថាបានទទួលថ្លៃជំនូនប៉ុន្មានដែរពីខាងស្វាមីអ៊ុំ?

ខ៖ អត់លោកគ្រូ អត់ចាំផង។

ក៖ អត់ចាំទេ?

ខ៖ អត់ចាំហើយមិនដែលបានម៉ែប៉ានិយាយប្រាប់ផង  មិនបានសួរស្អីៗពីគាត់ផង។

ក៖ ចុះអ៊ុំហេតុអីក៏ជ្រើសរើសរៀបការជាមួយគាត់ដែរកាលណឹង?

ខ៖ វាដូចមាននេះផងបើម៉ែប៉ាគាត់ថាឲ្យហើយ ថាគាត់ថាវាល្អបស់គាត់ហើយក៏ចឹងហើយតាមឪពុកម្ដាយទៅ។

ក៖ ចុះកាលពីក្មេងអ៊ុំបានទៅរៀនទេអ៊ុំ?

ខៈ អត់លោកគ្រូបានទៅរៀនអី ចុះបើយើងជំនាន់អាពតនោះបានរៀនអីចេះពីអាពត មកយើងធំបាត់ទៅហើយមិនដឹងទៅរៀនឯណាទៀត។

កៈ ចុះអ៊ុំចេះអាននិងចេះសរសេរអក្សរខ្មែរទេចឹង?

ខៈ អត់មិនចេះអីទេ។

កៈ ចុះអ៊ុំមានមិត្តភិក្តដែលស្និតស្នាលធំធាត់មកជាមួយគ្នាដល់សព្វថ្ងៃមានទេអ៊ុំ?

ខៈ មានប៉ុនងាប់អស់ហើយ មានផ្ទះនេះប៉ុន្តែងាប់បាត់ហើយងាប់ប៉ុន្មានខែមុនណឹង។

កៈ អរ! ឈ្មោះអ្វីដែរអ៊ុំ?

ខៈ ឈ្មោះ ញេប លែម ញេប។

កៈ មិត្តភិក្តអ៊ុំណឹង?

ខៈ ចាស។

កៈ ចុះអ៊ុំមានអនុស្សាវរីយ៍អីដែរជាមួយគាត់ណឹងអ៊ុំ?

ខៈ មានតែកាលជំនាន់អាពតណឹងឯងអ្នកគ្រូអើយយើងអត់មានឃ្លានគ្មានស៊ីអីទៅគេបញ្ជូនទៅក៏តែ២នាក់ អាថ្ងៃវៀតណាមវាយដាច់មកក៏ទៅត្រង់ណាក៏តែ២នាក់ដូចថាយើងទៅវាយមោងវាយអីអញ្ចឹងទៅក៏ តែ២នាក់ណឹងឯង ចាសនៅផ្ទះជិតគ្នាចេះទៅក៏ហៅគ្នាទៅអីទៅតែ២នាក់ណឹងឯងខ្ញុំមិនដែលមានអ្នកណាទៀតទេ ហើយម្យ៉ាងទៀតហៅថាមិត្តភិក្តមែនរាប់អានជិតដិតនិងម៉ែគាត់ម៉ែខ្ញុំអីចឹង ក៏ប៉ុន្តែដូចថាយើងទៅដើរលេងឆ្ងាយដូចក្មេងគេសព្វថ្ងៃខ្ញុំមិនដែលផង ប៉ុន្តែថាយើងនៅជិតគ្នាចឹងទៅបានអីហុចចែកគ្នាហូបអីចឹងទៅតែប៉ុណ្ណឹងឯង។

កៈ ចុះកាលនៅសម័យប៉ុល ពតវិញ ប៉ុល ពតឲ្យអ៊ុំធ្វើការងារអ្វីខ្លះដែរកាលណឹង?

ខៈ អូយ! អ្នកគ្រូមិនថាការងារអីទេវាឲ្យយើងបាអាចម៍ពីបង្គន់ វាឲ្យយើងកាប់អាស្អីអាដើមត្រផាងខែត្រគេយ៉ាងម៉េចនោះយកចញ្ច្រាំទៅ ចូកអាចម៍ណឹងមកយកមកលាយច្របល់លាយគ្នាទៅវាឲ្យយើងយកអាណឹងយកទៅបាចតាមស្រូវឲ្យនេះស៊ី ថ្ងៃឡើចឹងទៅឲ្យស្រូវនោះវាដុះ ថ្ងៃឡើងចឹងទៅស្រែណាដែលគេច្រូតរួចចឹងទៅ អរយើងរើសគួរស្រូវទៅ អូ!វាប្រើតែសព្វមុខណឹងឯងអ្នកគ្រូអើយ ត្រូវវាឲ្យយើងទៅរែកដីក៏រែកទៅ ត្រូវឲ្យយើងធ្វើក៏ធ្វើទៅតាមតែវាប្រើម៉ងយើងអត់មានសិទ្ធិតថ្លៃទេ យើងហ៊ានប្រកែកតែមួយម៉ាត់ដឹងតែងាប់ម៉ង មិនដែលពិបាកទេអ្នកគ្រូបើលោកគ្រូកើតទាន់វិញមិនបាច់ មិនដឹងថាវេទនានោះប៉ុណ្ណាទេ។

កៈ ចុះអ៊ុំមានបានទៅធ្វើស្រែ ច្រូត ស្ទូង ដកអីទេកាលណឹង?

ខៈ ច្រូតលោកគ្រូអើយដូចខ្ញុំនិយាយចឹង ចង់វាប្រើយើងទៅធ្វើអីយើងត្រូវធ្វើ បើថាយើងអត់ធ្វើដឹងតែវាយកយើងទៅសម្លាប់ ដូចឧបមាថាប្រើអ្នកគ្រូណាឥឡូវអ្នកគ្រូ ទៅបារអាចម៍បង្គន់នេះឥឡូវគ្នាប៉ុន្មាននាក់ ៣នាក់ ឬក៏នាក់អញ្ចឹង ធម្មតាយើងមិនរអៀក មិនស្អុយណាអ្នកគ្រូ ហើយចុះអន្លុងដីប៉ុណ្ណឹងនោះ ទៅវាឲ្យយើងបារពីណឹងមកយកមកដាក់និងកញ្ជេរមកវាឲ្យយើងចូកលាយអាដើមឈើដែលយើងចញ្ច្រាំណឹងនោះ ហើយយើងអត់ហ៊ានប្រកែកទេបើសិនជាយើងប្រកែកដឹងតែងាប់ម៉ង អូ!អត់ហ៊ានថាខ្ញុំមិនទៅទេស្អុយ អញ្ចេះមួយអញ្ចុះ២អីដឹងតែងាប់ហើយវាមិនឲ្យយើងរស់ទេ បានថាយ៉ាប់ចេះឯង បើថាកើតពីជំនាន់ណឹងទាន់ជំនាន់ណឹងអី មិនបាច់ថ្លែងទេលោកគ្រូ ចឹងបានតែខ្ញុំចេះតែនិយាយប្រាប់កូនចៅ ថាកូនកូនឯងសំបូរសប្បាយរាល់ថ្ងៃបានសំបូរសប្បាយពីជំនាន់ម្តាយវេទនាណាស់ វេទនាយ៉ាងម៉េច ខ្លះហើយបើខ្មោចយាយសឿៗណឹង ចាស់ដែរហើយកាលណឹង គាត់អត់មានអីពិសារចឹងដែលគាត់ល្ងើយណាស់ពេកទៅស្មារទោសគាត់អកដីខ្សាច់គាត់ថា អកដីខ្សាច់មាត់ចឹងទៅផឹកទឹកខ្ពុរៗចឹងទៅឲ្យធ្ងន់ពោះរ

អត់ងាយឃ្លាន វេទនណាស់អ្នកគ្រូ ក្តីលចេកក៏ឃើញស្អីក៏ឃើញថាអូ ថាអ្នកដែលរស់មកកាលមកសម័យនេះអ្នកគ្រូអាយុថ្លៃហើយ ថ្លៃណាស់ ចាសដូចថាអស់ពីកាកសំណល់ដែលវាសម្លាប់ហើយ បើកាលនៅវាបញ្ជូនទៅព្រៃកនរិទ្ធណាលោកគ្រូ យំតែម៉ោង១១ ទៅ១២អ្នកគ្រូ ហើយទ្វារបិទឲ្យឈឹងស្ងាត់ជ្រៀបមិនដែលមានហ៊ាននអ្នកណាហ៊ាននិយាយទេហើយកងឈ្លបវានៅតែក្រោមផ្ទះយើងណឹងទេ លបស្តាប់យើងខ្លាចយើងនិយាយអីចឹងឬមួយយើងដាំបាយ ឬមួយយើងធ្វើអីចឹង វាលបនៅតែក្រោមផ្ទះយើងណឹងតែព្រលប់មកទម្លាក់ទ្វារជិតឈឹងចឹងទៅអ្នកគ្រូហែកខ្ទមបាំងស្លឹកនោះចាសនៅជាប់មាត់ថ្នល់ចឹងហែកជញ្ជាំងមើលអញ្ចេះទៅ ចាសហែកជញ្ជាំងអើតមើល អញ្ចេះទៅអ្នកគ្រូយប់ម៉ោង១១ ១២ ម៉ោង១អ្នកគ្រូចាំមើលគេចងដៃតគ្នាចឹងទៅវា បណ្តើរទៅទាំងខ្សែៗទៅមួយខ្សែមាន១៤ ១៥នាក់ចឹងទៅ ចាសវាយកទៅសម្លាប់មានអាទូលមួយនៅក្រោយព្រៃកនរទ្ធិនោះ អ្នកគ្រូអើយទៅមើលទៅឆ្អឹងគរវាសម្លាប់ដូចថាមួយយប់ចេះ១៤ ១៥នាក់ចឹងទៅព្រឹកឡើងវាបង្គរភ្លើងរើសអុសរើសអីមកនិយាយពីវាដុតអុសសមកគេចាក់ពីលើខ្មោចទៅវាដុតទៅក៏ឆ្អឹងនៅសរស្វោច បានថាវេទនា ណាស់។

ក៖ បាទចុះតាំងពីក្មេងមកដល់ឥឡូវវិញអ៊ុំធ្លាប់បានប្រកបការងារអ្វីខ្លះដែរដើម្បីចិញ្ចឹមជីវិតនិងគ្រួសារដែរអ៊ុំ?

ខ៖ ហ៊ឺ អ្នកគ្រូចេះតែរកទៅមិនថា ជួនកាលទៅវាយមោងទៅ ត្រូវបេះបន្លែលក់ក៏បេះបន្លែលក់ទៅរើសអេតចាយក៏អេតចាយ មិនដែលរើសទេ ណាមួយរៀតណាមវាយដាច់មកប្តីពិការនេះឯង។

ក៖ គាត់ពិការដោយសារអ្វីដែរអ៊ុំ?

ខ៖ ជាមីនអាជំនាន់មួយហ៊ីដែរ កាលស្អីកាលរដ្ឋកម្ពុជាអាមួយហ៊ីបាញ់គ្នាណឹង ចាសសម័យរដ្ឋកម្ពុជាណឹងឯងទៅ នេះឡើងសមរភូមិទៅជាន់មីន។

ក៖ អញ្ចឹងតាំងពីក្មេងមកដល់ពេលនេះតើជីវិតអ៊ុំមានការផ្លាស់ប្ដូរអ្វីខ្លះដែរអ៊ុំ?

ខ៖ អើយអ្នកគ្រូវាដូចជាផ្លាស់ក៏ដូចជាមិនផ្លាស់តែប៉ុណ្ណោះឯងមានក៏មិនដែលស្គាល់ជាតិមាននិងគេយ៉ាងម៉េច ទេបើក្រជាងនេះមានបើថាឲ្យមានជាងនេះអត់ដែលមានទេ។

ក៖ ចុះកាលពីក្មេងអីអ៊ុំធ្លាប់មានក្ដីស្រម៉ៃថាធំឡើងចង់ធ្វើអីអត់ទេអ៊ុំ?

ខ៖ ចង់អ្នកគ្រូ ប៉ុន្តែយើងទៅអត់រូចណាមួយយើងអក្សរអត់ចេះ ណាមួយចង់ទៅរកប្រសិនជាយើងមានដើមអីតិចតួចយើងចង់រកស៊ីមុខជំនួញអីចឹង ទិញចូលលក់ចេញអីចឹងណាមួយយើងអត់អក្សរ អត់ចេះលេខ អត់ចេះអីចឹងទៅវាពិបាកក្នុងការរកស៊ីបើចឹងមានអញ្ចេះឯងទៅ មានតែប៉ុណ្ណឹងរាយមោងទៅ មានគេជួលច្រូតជួលស្ទូងអីក៏ទៅៗដែលយើងនៅកម្លាំងធំណាអ្នកគ្រូចាសតាំងអស់ពីកម្លាំងដែលវ័យចំណាស់នេះមកមានអីដើរបេះបន្លែទៅ ពឹងផ្អែកទៅលើលោកតែម្ដង។

ក៖ ចឹងទាក់ទងជាមួយចំណង់ចំណូលចិត្តអ៊ុំម្ដង តើអ៊ុំចូលចិត្តពិសារម្ហូបអ្វីជាងគេដែរអ៊ុំ? ឬក៏សម្លរណាជាងគេដែរតាំងពីក្មេងមកណា?

ខ៖ បើខ្ញុំតាំងពីក្មេងមកពិសេសជាងគេសម្លរម្ជូរ ហើយនិងត្រីខ អាខត្រីខយើងខសាច់ជ្រូកខអីណឹង ចាសហើយនិងសម្លរម្ជូរណឹងវាជ្រះមាត់។

ក៖ បាទ ចុះអ៊ុំចូលចិត្តស្ដាប់ចម្រៀងទេអ៊ុំ?

ខ៖ ធម្មតាអ្នកគ្រូមានទៅក៏ស្ដាប់ទៅ ហើយបើសិនជាថាចូលចិត្តស្ដាប់ទៅវិញគឺបទពីដើម។

កៈ បទអ្នកណាដែរអ៊ុំ?

ខៈ បទដូចថាបទសាមុតទៅ កែវ សារ៉ាត់ទៅ ណាយ វ៉ាន់ណេតទៅ បទពីដើមៗ បើបទសម័យនេះមិនសូវចូលចិត្តស្ដាប់គេទេគេចេញមកតែញ៉ាក់ៗចឹង។

កៈ បាទអ៊ុំ ចុះអ៊ុំមានចេះលេងឧបករណ៍តន្រ្តីទេអ៊ុំ?

ខៈ អត់លោកគ្រូទៅចេះស្អីបើអត់ចេះអក្សរផង។

កៈ ចុះកាលពីក្មេងៗ ឬក៏ក្រមុំអីអ៊ុំធ្លាប់បានទៅលេងល្បែងប្រជាប្រិយអ្វីខ្លះដែរតាមវត្តពេលភ្ជុំបិណ្ឌ ចូលឆ្នាំអ៊ុំ?

ខៈ បានតែទៅមើលគេអ្នកគ្រូមិនដែលលេងអីផង។

កៈ ម៉េចបានអត់លេងចឹង?

ខៈ ចុះបើអត់ចេះមិនដឹងលេងអី។

កៈ អញ្ចឹងមកដល់សព្វថ្ងៃនេះអ៊ុំមានកូនប៉ុន្មាននាក់ និងចៅប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ កូននៅ៤អ្នកគ្រូប៉ុន្តែគេបានប្ដីបែកផ្សេងអស់ហើយ មីនេះមួយ មីមួយលក់ចាប់ហួយត្រង់នេះមួយ ប៉ុនមីនោះនោះដូចថាឲ្យទៅមីងវាចុះ មីងវាអត់មានកូនចាសនៅជាមួយមីងវា បើនៅជាប់នេះ៣មីនេះមួយ ហើយនិងអាប្រុសនេះមួយ ហើយមីមួយទៀតគេបានប្ដីទៅនៅថ្នល់ដាច់នោះពៅគេ។

កៈ ចុះចៅប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ អូយ ចៅច្រើនណាស់ កូនមីបងនោះ៤ មីនេះ៦ មីនេះតិចជាងគេ៦ មីនៅថ្មល់ដាច់ឯនោះ៤ បើអានេះនេះ៣ ប្រពន្ធដើមមកបានមីក្រោយនេះទើបតែមានផ្ទៃពោះរ។

ក៖ បាទអ៊ុំច្រើនមែនទែនចឹង។

ខ៖ ច្រើនអ្នកគ្រូ។

ក៖ អញ្ចឹងមកដល់ចុងបញ្ចប់នេះតើអ៊ុំមានអ្វីចង់ផ្តាំផ្ញើទៅកាន់កូនចៅជំនាន់ក្រោយរបស់អ៊ុំ ឬក៏ទូន្មានទៅកាន់ពួកគេទេថាតើពួកគេគួរតែរស់នៅបែបណាឬក៏ធ្វើជាមនុស្សបែបណាដែរអ៊ុំ?

ខ៖ ថារាល់ថ្ងៃអ្នកគ្រូខ្ញុំសូមប្រាប់កូនប្រាប់ចៅ ប្រាប់ក្មួយទាំងអស់ញាតិជិតខាងថាដែលក្មេងៗសារក្រោយខ្ញុំសូមឲ្យថាសម័យនេះយើងសំបូរសប្បាយហើយកុំឲ្យដូចជំនាន់មុនហើយយើងសំបូរសប្បាយសុំឲ្យកូនចៅ កូនក្មួយសុំឲ្យដើរតែផ្លូវល្អកុំឲ្យដើរផ្លូវវេច ផ្លូវណាដែលច្បាប់គេទទួលស្គាល់តែម្តងអ្នកគ្រូ កុំដើរផ្លូវវេចព្រោះផ្លូវណឹងវាយ៉ាប់ យ៉ាប់ណាស់កុំចង់ ព្រោះខ្លាចតែវេទនាដូចខ្ញុំពីជំនាន់អាពតចឹង វេទនាដូចជំនាន់ណឹងបាយក៏គេបើក គេប្រើយើងដូចគោដូចក្របី ហើយសម័យនេះមានអ្នកណាប្រើយើងទៀត ចាសយើងមានសេរីភាពចង់ដើរ ចង់ហើរយើងចង់ស៊ី ចង់ចុក ចង់ចាយអត់មានអ្នកណាគេថាទេ បើចឹងហើយប្រាប់កូនប្រាប់ចៅថាកូនប្រឹងប្រែងយើងខំរកតែយើងខំរកយើងមាន បើជំនាន់ខ្ញុំវិញទោះបីរកប៉ុណ្ណាក៏មិនមានទៅណារកមកបានគេយកអស់ តែសំឡុយល្អគេមិនឲ្យយើងស្លៀកផងគេឲ្យយើងស្លៀកសំឡុយប្រឌិបជ្រលក់ជ័រតាកោររម៉េចទៀត ចឹងបានតែប្រាប់កូនប្រាប់ចៅថាកូនអើយកុំខំប្រឹងប្រែងរកស៊ីឲ្យមាន កុំឲ្យដូចម្តាយបើម្តាយនេះវាស្គាល់អស់ហើយប្រវិត្តជូរចត់។

ក៖ បាទអ៊ុំ ចឹងខ្ញុំសូមអរគុណដល់អ៊ុំដែលបានចំណាយពេលវេលសម្ភាសន៍ជាមួយខ្ញុំអ៊ុំណា ខ្ញុំសូមជូនពរឲ្យអ៊ុំមានសុខភាពល្អ មានសំណាងល្អ និងមានសុភមង្គលក្នុងក្រុមគ្រួសារអ៊ុំណា។

ខ៖ សាធុ សាធុ។